ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាល

# គោលនយោបាយជាតិ

# ស្តីពី

# ការគាំពារ និងអភិវឌ្ឍន៍កុមារតូច

353.536
POL
sh: Education

បណ្ណាល័យ
គ.ជ.អ.ប

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី

ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០

**រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា**

library.ncdd.gov.kh
009181

# សេចក្តីផ្តើម

កុមារតូចដែលចាប់ពីកកំណើតរហូតដល់អាយុក្រោម៦ឆ្នាំ តែងមានការអភិវឌ្ឍលើផ្នែករាងកាយ និងស្មារតី ដែលជាតម្រូវការចាំបាច់សម្រាប់កុមារ ។ ផ្នែកទាំងនេះ តែងលូតលាស់ទន្ទឹមគ្នា ហើយជះឥទ្ធិពលឱ្យគ្នាទៅវិញទៅមក ។

កុមារមានការអភិវឌ្ឍឆាប់រហ័សផ្នែកខួរក្បាលនៅឆ្នាំដំបូងនៃជីវិតរបស់គេ ។ បទពិសោធជាច្រើនបានបង្ហាញថា ជីវិតដំបូងរបស់កុមារត្រូវផ្តោតទៅលើការថែទាំ ការជួយទំនុកបម្រុងពីគ្រួសារ និងសង្គមឱ្យទទួលបាននូវសេវានានាដូចជា អាហារូបត្ថម្ភ ការថែទាំសុខភាព ការផ្តល់ឱកាសរៀនសូត្រ ការការពារពីគ្រោះថ្នាក់ផ្សេងៗ។ល។ ការងារទាំងនេះ អាចអនុវត្តបានជោគជ័យអាស្រ័យដោយមានគោលនយោបាយ និងមានការវិនិយោគដ៏សមស្របសម្រាប់កុមារតូច និងគ្រួសារ ។

រាជរដ្ឋាភិបាលតែងយល់អំពីសារៈសំខាន់នៃការគាំពារ និងអភិវឌ្ឍន៍កុមារតូច ដែលជាគុណប្រយោជន៏ដល់អនាគតរបស់កុមារម្នាក់ៗ ក្នុងការក្លាយខ្លួនទៅជាសសរទ្រូងនៃប្រទេសជាតិ ។ ការគាំពារ និងអភិវឌ្ឍន៏កុមារតូច ជាការងារអាទិភាព ហើយជាផ្នែកមួយខានមិនបាននៃការអប់រំសម្រាប់ទាំងអស់គ្នា ហើយក៏ជាយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ របស់រាជរដ្ឋាភិបាលផងដែរ ។

ប្រទេសកម្ពុជាមានប្រជាជនប្រមាណ ១៣.៤ លាននាក់ ក្នុងនោះស្ត្រីមានចំនួន ៥១.៣៦% និងមានប្រជាជនរស់នៅទីប្រជុំជនចំនួន ១៩.៥% ហើយប្រជាជនរស់នៅតាមជនបទមានចំនួន ៨០.៥% ជំរឿនឆ្នាំ២០០៨ ។ យើងបានកាត់បន្ថយភាពក្រីក្រពី ៤៧% ក្នុងឆ្នាំ១៩៩៣ មកត្រឹម ៣៤.៧% ក្នុងឆ្នាំ២០០៤ និងតាមការប៉ាន់ស្មានជាបឋមអាចចុះមកនៅត្រឹមប្រមាណ ៣០.១% ក្នុងឆ្នាំ២០០៧ ប៉ុន្តែអត្រានៃភាពក្រីក្រនៅជនបទ នៅមានកម្រិតខ្ពស់នៅឡើយ ។ រាជរដ្ឋាភិបាល បានលើកស្ទួយសុខុមាលភាពប្រជាជនទូទៅ ពិសេសប្រជាជនក្រីក្រ ស្ត្រី និងកុមារ ។ ជាលទ្ធផលអត្រាស្លាប់របស់ទារកបានថយចុះពី ៩៥ មកត្រឹម ៦៦ ក្នុង ១ ០០០ កំណើតរស់ នៅឆ្នាំ២០០០ និងអត្រាស្លាប់របស់កុមារក្រោមអាយុ៥ឆ្នាំ ក៏បានធ្លាក់ចុះមកត្រឹម ៨៣ ក្នុង ១ ០០០ កំណើតរស់ នៅឆ្នាំ២០០៥ ។ ប៉ុន្តែអត្រាមរណៈរបស់មាតាពេលសម្រាលកូននៅខ្ពស់នៅឡើយគឺ ៤៧២ ក្នុងកំណើតរស់ ១០០ ០០០នាក់ ។ ក្នុងឆ្នាំ២០០៥ ស្ត្រីមានផ្ទៃពោះលើសពី ៦៩% បានទទួលការថែទាំសុខភាពមួយដងយ៉ាងតិច មុនពេលសម្រាលកូន ។

ភស្តុតាងជាច្រើនបានឱ្យដឹងថា ការខ្វះអាហារូបត្ថម្ភ ខ្វះទម្ងន់ និងមានសុខភាពមិនល្អ ធ្វើឱ្យកុមារគ្មានសមត្ថភាពរៀនសូត្របានល្អ ។ អត្រាចូលរៀនរបស់កុមារតូចបានកើនឡើងពី ១០.៨% ក្នុងឆ្នាំ២០០៥ ទៅ ១៥.៦% ក្នុងឆ្នាំ២០០៨ ។ ការសិក្សាស្រាវជ្រាវជាច្រើនបានឱ្យដឹងថា កុមារដែលបានឆ្លងកាត់ថ្នាក់

មត្តេយ្យសិក្សា តែងតែបានចូលរៀនទៅសាលាបឋមសិក្សានៅអាយុ៦ឆ្នាំ ហើយភាគច្រើនរៀនចប់បឋម សិក្សា ដោយពុំមានការត្រួតថ្នាក់ និងបោះបង់ការសិក្សា ។

រដ្ឋធម្មនុញ្ញ ច្បាប់ និងគោលនយោបាយនៃព្រះរាជាណាចក្រកម្ពុជា បានគូសបញ្ជាក់អំពីការយកចិត្តទុកដាក់លើការគាំពារ ថែទាំ និងអប់រំកុមារ ជាអាទិ៍មាត្រា៤៨នៃរដ្ឋធម្មនុញ្ញបានចែងថា "រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មាន សង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ ។ រដ្ឋគាំពារ ប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខុមាលភាពរបស់កុមារ" ។

ដើម្បីសម្រេចចក្ខុវិស័យ និងយុទ្ធសាស្ត្រនៃការគាំពារ និងអភិវឌ្ឍន៍កុមារតូច ទាមទារឱ្យមានការតាមដាន សម្រាប់វាយតម្លៃលើការរីកចម្រើន នៃការអនុវត្តគោលនយោបាយ ។

# ជំពូកទី១

# ចក្ខុវិស័យ

## I. ចក្ខុវិស័យ

កុមារតូចទាំងអស់ចាប់ពីកកំណើតរហូតដល់អាយុក្រោម៦ឆ្នាំ ត្រូវទទួលបានសេវាគាំពារ និងអភិវឌ្ឍ ជាពិសេសកុមារតូចរងគ្រោះ កុមារតូចងាយរងគ្រោះ និងក្រខ្សត់ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

## II. គោលបំណង និងគោលដៅ

១-ស្ត្រីទាំងអស់ទទួលបាន នូវសេវាថែទាំនិងសេវាអប់រំសុខភាព ព្រមទាំងអាហារូបត្ថម្ភនៅពេលមានផ្ទៃពោះ។

២- កុមារតូចទាំងអស់ទទួលបានការចុះបញ្ជីកំណើត ការថែទាំ ពិនិត្យសុខភាពជាប្រចាំ ថ្នាំបង្ការគ្រប់គ្រាន់ អាហារូបត្ថម្ភគ្រប់គ្រាន់ និងទទួលបានការហាត់រៀនពីដំបូង។

៣-កុមារតូចទាំងអស់មានលក្ខណៈត្រៀមជាស្រេចដើម្បីចូលរៀនថ្នាក់ទី១ នៅអាយុ៦ឆ្នាំ។

៤- បុគ្គលិកបច្ចេកទេស អ្នកថែទាំកុមារតូច មាតាបិតា និងអ្នកអាណាព្យាបាល ដែលមានចំណេះដឹងគ្រប់គ្រាន់លើការគាំពារ និងអភិវឌ្ឍន៍កុមារតូច។

៥- គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធទាំងអស់ សហការគ្នាយ៉ាងជិតស្និទ្ធ ដើម្បីដោះស្រាយបញ្ហា ដែលទាក់ទងនឹងការគាំពារ និងអភិវឌ្ឍន៍កុមារតូច។

៦- កុមារតូច ចាប់ពីពេលប្រសូតរហូតដល់ពេលចូលរៀន មានការរីកចម្រើនផ្នែករាងកាយ ចំណេះដឹង ប្រាជ្ញា និងអារម្មណ៍នៅតាមផ្ទះរបស់ខ្លួន ព្រមទាំងតាមមណ្ឌលដែលផ្តល់សេវាសុខភាព អាហារូបត្ថម្ភ និងអប់រំប្រកបដោយគុណភាព និងនិរន្តរភាព។

# ជំពូកទី២

# យុទ្ធសាស្ត្រ

យុទ្ធសាស្ត្រសំខាន់ៗ ដើម្បីសម្រេចគោលបំណង និងគោលដៅខាងលើ មានដូចខាងក្រោម៖

១-រៀបចំក្របខណ្ឌច្បាប់ បទដ្ឋាន និងយន្តការ ដើម្បីគាំទ្រ និងអនុវត្តគោលនយោបាយឱ្យមានប្រសិទ្ធភាព ដោយកំណត់ឱ្យមានកិច្ចសហការ និងភារកិច្ចរបស់ភាគីពាក់ព័ន្ធសំខាន់ៗ។

២- កែលម្អយន្តការតាមដានវាយតម្លៃ ដែលមានស្រាប់ឬបង្កើតថ្មី ដោយមានការចូលរួមពីក្រសួង ស្ថាប័ន សហគមន៍ ដៃគូអភិវឌ្ឍនានា និងកែលម្អគណៈកម្មការសម្របសម្រួលបច្ចេកទេស

ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយបែងចែកភារកិច្ច និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់។

៣- កសាងសមត្ថភាព (បណ្តុះបណ្តាលមុន និងកំពុងបម្រើការងារ) អ្នកអនុវត្តកម្មវិធី មាតាបិតា អ្នកអាណាព្យាបាល និងអ្នកគ្រប់គ្រងថែរក្សាកុមារលើខ្លឹមសារ និងវិធីថែទាំឱ្យស្របតាមកម្មវិធីសិក្សា និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

៤- បង្កើតយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីផ្តល់វិញ្ញាបនបត្រ ឬ លិខិតទទួលស្គាល់ដល់អ្នកអនុវត្តកម្មវិធី ទៅតាមសេវាថែទាំជាក់ស្តែង។

៥- បង្កើនសេវា និងការអប់រំស្តីអំពីការថែទាំសុខភាព និងអាហារូបត្ថម្ភដល់ស្ត្រីទាំងអស់ដែលមានផ្ទៃពោះ។

៦- បង្កើនសេវាថែទាំព្យាបាលសុខភាព ជំងឺ ដល់កុមារតូចចាប់ពីពេលកើតដល់អាយុ៣ឆ្នាំ ដោយពិនិត្យសុខភាពជាប្រចាំ ផ្តល់ថ្នាំបង្ការទាន់ពេល និងពេញលេញ ហើយតាមដានការផ្តល់សេវាអាហារូបត្ថម្ភ ចំពោះកុមារដែលខ្វះអាហារូបត្ថម្ភ មានជំងឺរ៉ាំរ៉ៃ លូតលាស់យឺត ពិការ។

៧- ពង្រីកការផ្តល់សេវាគាំពារ និងអភិវឌ្ឍកុមារតូចរួមមាន សេវារដ្ឋ សេវាសហគមន៍ សេវាឯកជន តាមផ្ទះ និងតាមខ្នងផ្ទះ ជាពិសេសការហាត់រៀនពីដំបូងចំពោះកុមារតូច។

៨- ធានាឱ្យគ្រប់គ្រួសារទទួលបានព័ត៌មាន និងសេវាដូចជា ទឹកស្អាតនិងអនាម័យ សុខភាព អាហារូបត្ថម្ភ ការបំបៅកូនដោយទឹកដោះម្តាយ ការផ្តល់អាហារបន្ថែម ការទទួលថ្នាំបង្ការ ជីវជាតិអា ជាតិដែក និងអំបិលអ៊ីយ៉ូដ ការរៀនពីដំបូង ការចុះបញ្ជីកំណើត ការទប់ស្កាត់ជំងឺឆ្លងគ្រប់ប្រភេទមានជាអាទិ៍ មេរោគអេដស៍និងជំងឺអេដស៍ ជំងឺគ្រុនចាញ់ ការការពារគ្រួសារពីអំពើហិង្សា និងការរងគ្រោះដោយប្រការផ្សេងៗ។

៩-បង្កើតឱ្យមានយន្តការផ្សព្វផ្សាយព័ត៌មានអំពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច សម្រាប់ទាក់ទាញការគាំទ្រសេវាទាំងនេះ។

## ជំពូកទី៣

## គោលនយោបាយ និងការអនុវត្ត

### I. គោលនយោបាយ

គោលនយោបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច មានខ្លឹមសារសំខាន់ដូចខាងក្រោម៖

១- ធានាការផ្តល់សេវាសម្រាប់ការគាំពារ និងអភិវឌ្ឍន៍កុមារតូច ចាប់ពីកកំណើតរហូតដល់អាយុក្រោម៦ឆ្នាំ

២- ធានាឱ្យកុមារតូចមានការគាំពារ និងអភិវឌ្ឍន៍ពេញលេញលើគ្រប់ផ្នែក

៣-ធានាឱ្យក្រសួង ស្ថាប័នសាធារណៈ និងសង្គមស៊ីវិលពាក់ព័ន្ធទាំងអស់ សហការគ្នា សម្រាប់ការគាំពារ និងអភិវឌ្ឍន៍កុមារតូច ។

## II. ការអនុវត្ត

ក្រសួងអប់រំ យុវជន និងកីឡា មានតួនាទីសំខាន់ក្នុងការដឹកនាំ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ ព្រមទាំងសង្គមស៊ីវិលក្នុងបំណងសហការអនុវត្តតួនាទី ភារកិច្ច ដើម្បីគាំទ្រការគាំពារ និងអភិវឌ្ឍន៍កុមារតូចឱ្យមានប្រសិទ្ធភាព ។

### ១._ក្រសួងអប់រំ យុវជន និងកីឡា

១.១- បង្កើតឯកសារ និងសម្ភារៈល្បែង ដើម្បីគាំពារ និងអភិវឌ្ឍកុមារតូច ។

១.២- ផ្តល់បច្ចេកទេសផ្នែកមត្តេយ្យសិក្សា និងកម្មវិធីអភិវឌ្ឍកុមារតូចផ្សេងៗទៀត ដើម្បីជាគំរូសម្រាប់យកទៅអនុវត្ត ។

១.៣-បង្កើតបទដ្ឋានផ្សេងៗសម្រាប់ការគាំពារ និងអប់រំកុមារតូច (សម្ភារៈល្បែង សួនកុមារ...) ។

១.៤-ធានាគុណភាពនៃការគាំពារ និងអភិវឌ្ឍន៍កុមារតូច តាមរយៈការបណ្តុះបណ្តាលប្រកបដោយគុណភាពដល់គ្រូមត្តេយ្យសិក្សា អ្នកសម្របសម្រួល និងបុគ្គលិកពាក់ព័ន្ធដទៃទៀត ។

១.៥- ផ្សព្វផ្សាយពីការប្រើប្រាស់សម្ភារៈល្បែង ដើម្បីធានាសុវត្ថិភាពកុមារតូច ។

១.៦- សម្របសម្រួលការអនុវត្តកម្មវិធីជាមួយនឹងក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ។

### ២._ក្រសួងសុខាភិបាល

២.១- សម្របសម្រួលបច្ចេកទេសជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបង្កើតឯកសារស្តីពីសុខភាព និងអាហារូបត្ថម្ភ និងបណ្តុះបណ្តាលអ្នកសម្របសម្រួលរួមទាំងគ្រូមត្តេយ្យសិក្សា ។

២.២- អប់រំមាតាបិតាអំពីការថែរក្សាសុខភាពមាតា និងទារករួមទាំង សារៈសំខាន់នៃការបំបៅកូនដោយទឹកដោះម្តាយ និងការទទួលសារជាតិអ៊ីយ៉ូដ ដែក អាស៊ីតហ្វូលីក ជីវជាតិអា និងមីក្រូសារជាតិដទៃទៀតឱ្យបានគ្រប់គ្រាន់ ។

២.៣- បញ្ចូលផ្នែកគាំពារ និងអភិវឌ្ឍកុមារតូចទៅក្នុងវគ្គបណ្តុះបណ្តាលគិលានុបដ្ឋាយិកា និងមន្ត្រីសុខាភិបាល ។

២.៤- ធានាឱ្យមានការផ្តល់ថ្នាំបង្ការជំងឺផ្សេងៗ និងធានាឱ្យមានសិទ្ធិរស់រានមានជីវិតនិងលូតលាស់សម្រាប់កុមារទាំងអស់ ។

២.៥- ធានាឱ្យបាននូវការអភិវឌ្ឍសុខភាព និងរាងកាយកុមារតាមរយៈការផ្តល់សេវាសុខភាពជាមូលដ្ឋាន ។

២.៦- ផ្តល់ធនធានបច្ចេកទេស និងចូលរួមសកម្មភាពនៅក្នុងការអប់រំសុខភាពសហគមន៍ ។

## ៣._ក្រសួងមហាផ្ទៃ

៣.១- ធ្វើការជំរុញ ពិនិត្យតាមដាន និងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ (គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់) ឱ្យអនុវត្តសេចក្តីណែនាំរបស់ក្រសួង ។

៣.២-ចូលរួមសហការជាមួយនឹងក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ ដើម្បីរៀបចំបច្ចុប្បន្នភាពសេចក្តីណែនាំសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់អនុវត្តគោលនយោបាយគាំពារ និងអភិវឌ្ឍន៍កុមារតូច ។

៣.៣-ចូលរួមក្នុងការវាយតម្លៃលើសេវាគាំពារ និងអភិវឌ្ឍកុមារតូច ។

៣.៤- ណែនាំក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យយកចិត្តទុកដាក់លើបញ្ហា និងតម្រូវការជាអាទិភាពពាក់ព័ន្ធនឹងការគាំពារ និងអភិវឌ្ឍន៍កុមារតូច ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។

## ៤._ក្រសួងកិច្ចការនារី

៤.១- លើកទឹកចិត្ត គាំទ្រ កែលម្អ បង្កើតសេវាគាំពារ និងអភិវឌ្ឍកុមារតូច ប្រកបដោយគុណភាពសម្រាប់គ្រួសារទូទៅដែលត្រូវការចាំបាច់នូវសេវាទាំងនេះ ពិសេសសម្រាប់មាតា ដែលជាប់មមាញឹកនឹងការងារ ហើយត្រូវការឱ្យមានអ្នកថែទាំកូន តាមរយៈការដាក់បណ្តាញជាមួយស្ថាប័នរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍនានា ។

៤.២- ផ្សព្វផ្សាយអប់រំ ពីសារៈសំខាន់នៃការអប់រំស្ត្រីនិងក្មេងស្រី ដើម្បីធានាឱ្យបាននូវសមភាព និងសមធម៌យេនឌ័រនៅគ្រប់កម្រិត/សារៈសំខាន់នៃការគាំពារ និងអភិវឌ្ឍន៍កុមារ និងបង្កើនការយល់ដឹងអំពីសិទ្ធិស្ត្រី និងសិទ្ធិកុមារ តាមគ្រប់មធ្យោបាយ ។

៤.៣-លើកកម្ពស់សមត្ថភាពមន្ត្រីគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ អ្នកសម្របសម្រួល អ្នកថែទាំ អ្នកស្ម័គ្រចិត្ត និងមាតាបិតានៅសហគមន៍លើសេវាថែទាំសុខភាពបឋម ជំនាញបំណិនជីវិត និងការបញ្ជ្រាបយេនឌ័រ ។

## ៥._ក្រសួងព័ត៌មាន

៥.១- បង្កើតប្រព័ន្ធព័ត៌មានដើម្បីផ្សព្វផ្សាយរាល់ព័ត៌មានទាំងឡាយ ស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ។

៥.២- ពង្រីក និងពង្រឹងបណ្តាញផ្សព្វផ្សាយ ដែលមានតួនាទីសំខាន់ ក្នុងការលើកឡើងអំពីចំណុចសំខាន់ៗនៃសិទ្ធិកុមារ រួមទាំងបញ្ហាស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ផ្តល់ព័ត៌មានស្តីពីការអប់រំមាតាបិតា ។

៥.៣- សហការបង្កើតកម្មវិធីកុមារប្រកបដោយគុណភាពសម្រាប់ជាការអប់រំ និងការកម្សាន្តសប្បាយ ។

## ៦._ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

៦.១- គាំទ្រការអនុវត្តគោលនយោបាយថែទាំជំនួសចំពោះកុមារ និងបទដ្ឋានផ្សេងៗ សម្រាប់ការថែទាំជំនួសចំពោះកុមារដែលស្ថិតក្នុងមណ្ឌល និងក្នុងសហគមន៍ ។

៦.២- ជំរុញឱ្យទារកកំព្រា កុមារកំព្រា កុមារពិការ កុមារគ្មានទីពឹង ទទួលបានសេវាចិញ្ចឹមបន្តនៅក្នុងមណ្ឌលកុមារកំព្រារដ្ឋ ឬមណ្ឌលរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលជាកន្លែងផ្តល់សេវាស្នាក់នៅ ចិញ្ចឹមថែទាំសុខភាព អប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្ម ។

៦.៣- ជំរុញអ្នកដែលមានភារកិច្ចចិញ្ចឹមកុមារទទួលបានសេវាបណ្តុះបណ្តាលផ្នែកចិត្តសាស្ត្រ និង ជំនាញស្តីពីការថែទាំកុមារ ។

៦.៤- ជំរុញឱ្យកុមារទាំងអស់ដែលរស់នៅក្នុងមណ្ឌលកុមារកំព្រារដ្ឋ និងមណ្ឌលរបស់អង្គការមិនមែនរដ្ឋាភិបាល ឬសហគមន៍ ដែលគ្រប់អាយុចូលសិក្សានៅសាលាមត្តេយ្យសិក្សាបានចូលរៀនទាំងអស់គ្នា ដើម្បីរៀបចំត្រៀមចូលរៀនកម្រិតបឋមសិក្សា ។

៦.៥- បញ្ចូលផ្នែកគាំពារ និងអភិវឌ្ឍកុមារតូច ទៅក្នុងកម្មវិធីស្តារលទ្ធភាព/បណ្តាញការពារកុមារនៅសហគមន៍ និងកម្មវិធីផ្សេងៗទៀតរបស់ក្រសួង ។

៦.៦- ជំរុញការតស៊ូមតិ ក្នុងការដាក់បញ្ចូលតម្រូវការរបស់កុមារក្នុងផែនការអភិវឌ្ឍជាតិគ្រប់កម្រិត ។

៦.៧- បន្តពង្រឹងសកម្មភាព ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដែលជាយន្តការ សម្របសម្រួលរវាងក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីការពារកុមារតូច ។

## ៧._ក្រសួងអភិវឌ្ឍន៍ជនបទ

៧.១-លើកទឹកចិត្តឱ្យមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត សម្របសម្រួល ពិនិត្យតាមដាន និងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ។

៧.២-សហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីពង្រឹងគណៈកម្មាធិការអភិវឌ្ឍភូមិឱ្យខិតខំអស់លទ្ធភាព

រកគ្រប់មធ្យោបាយ ដើម្បីដោះស្រាយបញ្ហានៅក្នុងសហគមន៍របស់ខ្លួន តាមរយៈការប្រើប្រាស់ទឹកស្អាត អនាម័យ សន្តិសុខស្បៀង អាហារូបត្ថម្ភ អនាម័យបរិស្ថាន និងឥណទានជនបទ ។

៧.៣-ជំរុញការកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ តាមរយៈការកសាងផ្លូវជនបទ ការផ្គត់ផ្គង់ ទឹកស្អាត បង្គន់អនាម័យ ដើម្បីជួយសម្រួលដល់សុខុមាលភាពរបស់ស្ត្រី និងកុមារ ។

## ៨._ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចចូលរួមលើផ្នែកគាំពារ និងអភិវឌ្ឍកុមារតូច តាមរយៈការផ្តល់មូលនិធិបានទាន់ពេលវេលា ដល់សកម្មភាពគាំពារ និងអភិវឌ្ឍកុមារតូច ។

## ៩._ក្រសួងផែនការ

៩.១- សម្របសម្រួល និងចងក្រងកម្រងសូចនាករជាតិ សម្រាប់ការដាក់ទិសដៅក្នុងកិច្ចការ គាំពារ និងអភិវឌ្ឍន៍កុមារតូច ។

៩.២- សម្របសម្រួល និងឯកភាពលើគោលការណ៍ វិធីសាស្ត្រ និងការប្រមូលទិន្នន័យ សម្រាប់ពិនិត្យតាមដានវាយតម្លៃលើការអនុវត្តផែនការ និងកម្មវិធីដែលបានកំណត់ ។

៩.៣-សម្របសម្រួលនិងចងក្រងផែនការគាំពារ និងអភិវឌ្ឍកុមារតូច ឱ្យទៅជាផែនការជាតិ ។

៩.៤- ផ្សព្វផ្សាយតួលេខ និងសូចនាករជាតិដែលជាលទ្ធផលនៃការអនុវត្តផែនការ និងទិសដៅ នៃការគាំពារ និងអភិវឌ្ឍន៍កុមារតូចឱ្យបានទូលំទូលាយ និងប្រកបដោយប្រសិទ្ធភាព ។

## ១០._ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១០.១- ជំរុញ និងបង្កើនការកែលម្អលទ្ធភាពកសិកម្ម និងពិពិធកម្មកសិកម្មដល់មាតាបិតា អ្នកអាណាព្យាបាល និងអ្នកគ្រប់គ្រងថែរក្សា តាមរយៈភ្នាក់ងារផ្សព្វផ្សាយកសិកម្មគ្រប់កម្រិត ។

១០.២-ពង្រីក និងពង្រឹងសមត្ថភាពភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ភ្នាក់ងារសុខភាពសត្វភូមិ និងសហគមន៍មូលដ្ឋាននានា ដើម្បីជួយដល់មាតាបិតា អ្នកអាណាព្យាបាល និងអ្នកគ្រប់គ្រងថែរក្សាឱ្យមានមូលដ្ឋាន ក្នុងការបង្កើនផលិតភាពកសិកម្ម តាមធនធានដែលមានឱ្យអស់លទ្ធភាព រួមទាំងការអភិវឌ្ឍសួនបន្លែ ការចិញ្ចឹមសត្វ និងដំណាំចម្រុះជុំវិញគេហដ្ឋានជាដើម ។

១០.៣-បង្កើនសមត្ថភាពមាតាបិតាទាំងឡាយឱ្យចេះទុកដាក់ និងចេះប្រើប្រាស់សារធាតុជំនួយសម្រាប់បង្កបង្កើនស្បៀងស្របតាមបច្ចេកវិទ្យា ដើម្បីធានាសុវត្ថិភាពស្បៀងដល់អ្នកប្រើប្រាស់ និងអ្នកបរិភោគ ជាពិសេសកុមារតូច ។

១០.៤-យកចិត្តទុកដាក់ចំពោះគ្រប់រូបភាព នៃការផ្សព្វផ្សាយកសិកម្មទាំងអស់ ដើម្បីជាប្រយោជន៍

ដល់ស្ត្រី និងកុមារ ដូចជាការផ្សព្វផ្សាយពីជំងឺគ្រុនផ្តាសាយបក្សី ការផ្សព្វផ្សាយពីសុវត្ថិភាពការប្រើប្រាស់ថ្នាំកសិកម្ម និងការប្រើប្រាស់ជីកសិកម្មជាដើម ។

## ១១._ក្រសួងបរិស្ថាន

១១.១-មាតាបិតា ឬអ្នកអាណាព្យាបាល ត្រូវអនុវត្តជាប្រចាំនូវគំរូល្អ ក្នុងកិច្ចគាំពារបរិស្ថាន ដើម្បីឱ្យកុមារតូចៗ បានឃើញ និងយល់ដឹងពីសារៈប្រយោជន៍នៃបរិស្ថាន ។

១១.២-ផ្សព្វផ្សាយដល់សហគមន៍ មាតាបិតា អាណាព្យាបាលឱ្យយល់ដឹងពីផលប៉ះពាល់សុខភាព និងចេះទុកដាក់ប្រើប្រាស់សារធាតុពុលសម្រាប់ដំណាំផ្សេងៗដើម្បីធានាសុវត្ថិភាពដល់អ្នកប្រើប្រាស់ និងបរិស្ថាន ជាពិសេសកុមារតូចៗ ។

១១.៣-ជំរុញលើកកម្ពស់សុខភាពបរិស្ថាន ដើម្បីសុខុមាលភាពរបស់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី និងកុមារ ។

១១.៤- ទប់ស្កាត់និងការពារ ការបំពុលបរិស្ថានគ្រប់រូបភាព ដែលនាំឱ្យប៉ះពាល់ដល់ការគាំពារ និងអភិវឌ្ឍន៍កុមារតូច ។

១១.៥-ផ្សព្វផ្សាយនិងលើកកម្ពស់ការយល់ដឹងដល់មាតាបិតា អ្នកអាណាព្យាបាល និងលោកគ្រូ អ្នកគ្រូសំដៅបង្កើតការអប់រំដល់កុមារតូចៗ ក្នុងការចូលរួមធ្វើអនាម័យបរិស្ថានតាមលំនៅឋាន សាលារៀន ទីសាធារណៈ និងអំពីផលប៉ះពាល់ដល់សុខុមាលភាព និងភ័យន្តរាយនានា ។

## ១២._មាតាបិតា និងគ្រួសារ

១២.១- ស្វែងរកចំណេះដឹងនិងបំណិនចាំបាច់ក្នុងការថែទាំកូន ។

១២.២- បញ្ជូនកូនទៅកន្លែងដែលមានកម្មវិធីគាំពារ និងអភិវឌ្ឍកុមារតូច ។

១២.៣- បង្ហាញអំពីតម្រូវការរបស់ខ្លួន ជួយឧបត្ថម្ភដល់ការបង្កើតកម្មវិធីគាំពារ និងអភិវឌ្ឍកុមារតូចនៅក្នុងភូមិ និងចែករំលែកបទពិសោធដែលពួកគេចេះដល់គ្រួសារឯទៀត ។

១២.៤- ត្រួតពិនិត្យតាមដាន និងវាយតម្លៃការលូតលាស់របស់កុមារលើផ្លូវកាយ និងប្រាជ្ញា ។

១២.៥- មិនត្រូវប្រើអំពើហិង្សាក្នុងគ្រួសារ ជាពិសេសកុមារតូច ។

## ១៣._ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល

១៣.១- ជួយគាំទ្រសេវាគាំពារ និងអភិវឌ្ឍកុមារតូចក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធតាមសហគមន៍ ។

១៣.២- គាំទ្រគំរូថ្មីៗនៃកម្មវិធីគាំពារ និងអភិវឌ្ឍកុមារតូច ដោយសហការជិតស្និទ្ធជាមួយនឹងរាជរដ្ឋាភិបាល ។

១៣.៣- ជួយគាំទ្រវគ្គសិក្សាសម្រាប់គ្រូមត្តេយ្យសិក្សា អ្នកសម្របសម្រួលការគាំពារ និង អភិវឌ្ឍន៍កុមារតូច និងមាតាបិតា ។

១៣.៤- រៀបចំបណ្ដាញការងារជាមួយនឹងដៃគូអភិវឌ្ឍ ដែលធ្វើការផ្នែកគាំពារ និងអភិវឌ្ឍន៍កុមារតូចដទៃទៀត ដើម្បីចែករំលែកព័ត៌មាន និងបទពិសោធឱ្យគ្នាទៅវិញទៅមក ។

១៣.៥- គាំទ្រនិងផ្ដល់ជំនួយដល់កម្មវិធីគាំពារ និងអភិវឌ្ឍកុមារតូច ដែលមានគោលដៅនៅតំបន់ក្រីក្រ និងជួបការលំបាក ។

# សេចក្តីសន្និដ្ឋាន

ការគាំពារ និងអភិវឌ្ឍន៍កុមារតូច ជាបញ្ហាដែលត្រូវយកចិត្តទុកដាក់បំផុត ព្រោះកុមារតូចងាយទទួលគ្រោះថ្នាក់ផ្សេងៗ ដែលត្រូវប្រឈម ។

ដើម្បីសម្រេចបាននូវគោលនយោបាយនេះ ទាមទារត្រូវ ៖

- មានយន្តការ បទដ្ឋានគតិយុត្ត សម្រាប់បង្កើតគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច និង គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ។ ឯកសារនេះត្រូវបញ្ចូលលក្ខខណ្ឌតម្រូវការចាំបាច់មួយចំនួនដូចជា រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី ភារកិច្ច របស់គណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច និងរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ ជាដើម
- រៀបចំផែនការសកម្មភាពជាតិសម្រាប់លើកកម្ពស់ការគាំពារ និងអភិវឌ្ឍន៍កុមារតូច ដោយបញ្ចូលនូវសកម្មភាព និងថវិកាលម្អិត
- កៀរគរជំនួយពីគ្រប់មជ្ឈដ្ឋាន ។

ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ត្រូវរួមចំណែកជំរុញ និងអនុវត្តគោលនយោបាយជាតិ ស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចឱ្យមានប្រសិទ្ធភាពខ្ពស់ ហើយត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ និងដៃគូអភិវឌ្ឍនានា ក្នុងគោលបំណងលើកទឹកចិត្តឱ្យមានការចូលរួមអនុវត្តបានជោគជ័យ ។

# ឧបសម្ព័ន្ធ

១. **ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ** : ជាយន្តការមួយមានភារកិច្ច ពិគ្រោះយោបល់ សម្របសម្រួល ផ្សព្វផ្សាយ រៀបចំរបាយការណ៍ និងពិនិត្យតាមដានវាយតម្លៃលើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

២. **គណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច** : ជាយន្តការអនុវត្តគោលនយោបាយជាតិគាំពារ និងអភិវឌ្ឍកុមារតូច ដើម្បីឆ្លើយតបនឹងច្បាប់ស្តីពីការអប់រំ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

៣. **គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ** : គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ មានសិទ្ធិ និងមានភារកិច្ចផ្តល់យោបល់និងលើកអនុសាសន៍ជូនក្រុមប្រឹក្សា គណៈអភិបាល អភិបាល និងគណៈកម្មាធិការដទៃទៀតរបស់ក្រុមប្រឹក្សាលើបញ្ហាពាក់ពន្ធ័នឹងសមភាពយេនឌ័រ បញ្ហាស្ត្រី និងកុមារដែលស្ថិតក្នុងអំណាចមុខងារ និងភារកិច្ចរបស់ក្រុមប្រឹក្សា ។

# NATIONAL POLICY

## ON

## EARLY CHILDHOOD CARE AND DEVELOPMENT

Endorsed by Council of Ministers
During a Plenary Session on 19 February 2010
Prepared by the Ministry of Education, Youth and Sport

# Introduction

During early childhood from the conception to age under six, children experience physical and emotional development, which is their fundamental need. This development always grows in a simultaneous and inter-connected affect.

Rapid brain development occurs during the early years of life. Many experiences showed that in the early years, young children require care, support from their families and society so that they can have access to various services such as nutrition, health care, learning opportunities, protection from risks etc. Such works can be successfully undertaken when children and their families are supported by a policy and appropriate investment.

The Royal Government of Cambodia always recognizes the importance of early childhood care and development (ECCD) that is the advantageous values for the future of the children who will be pillars of the country. Early childhood care and development is the priority and indispensable element of Education for All (EFA) and Poverty Reduction Strategy of the Royal Government of Cambodia.

According to the population census conducted in 2008, the total population of Cambodia was 13.4 million, 51.36% of them were women. About 19.5% of the population lived in the urban areas and the remaining 80.5% lived in the rural areas. The poverty rate was reduced from 47% in 1993 to 34.7% in 2004. Although a primary estimated poverty rate would further decrease to 30.1% in 2007, but the poverty in rural areas remain high. The Royal Government of Cambodia has tried to improve the welfare of the people, in particular the poor, women and children. As a result, infant mortality rate declined from 95 in 2000 to only 66 per 1,000 live births, and mortality rate among children under 5 years old decreased to 83 per 1,000 live births in 2005. However, the maternal mortality rate is still high at 472 per 100,000 live births. In 2005, more than 69% of pregnant women were provided with health care by health practitioners at least once before birth delivery.

There are growing evidences that children who experiences malnutrition, underweight and unhealthiness are less likely to perform well at school. The Early childhood enrolment rate increased from 10.8% in 2005 to 15.6% in 2008. According to surveys, children who experience preschools

usually start their primary education at the age of six and the majority of them manage to complete their primary levels without repetition and school dropout.

The constitution, laws and policies of the Royal Government of Cambodia draw attention to children care and education of children. For instance, Article 48 of the constitution states that "The State shall ensure protection the rights of the children as stipulated in the Convention on Children, in particular, the rights to life, education, protection during wartime, and from economic or sexual exploitation. The State shall protect children from acts that are injurious to their educational opportunities or that is detrimental to their welfare."

In order to reach the vision and strategies of the early childhood care and development, monitoring system for progressive evaluation of policy implementation is needed.

# Chapter 1

# VISION

## I. Vision

All Cambodian children, from conception to aged under six, especially disadvantaged, vulnerable and poor children, shall be provided with care and development services, in line with the Constitution of the Kingdom of Cambodia.

## II. Goal and Objectives

1. All women are provided with care, health education services and nutrition during pregnancy;
2. All children have their births registered, are provided with care, regular health checkup, adequate immunization and nutrition, and early learning;
3. All early children are ready to start grade 1 at age six;
4. Technical staffs, care givers, parents and guardians with appropriate knowledge on early childhood care and development;
5. All relevant ministries/institutions work together closely to address and deal with the issues concerning early childhood care and development; and
6. All early children from birth to schooling age shall enjoy physical, cognitive, mental and emotional development at own home and centers which provide quality and sustainable health services, nutrition and education.

# Chapter 2

# STRATEGIES

Major strategies to reach above goal and objectives are as followings:

1. Prepare legal framework, standards and mechanisms to effectively support and implement the policy, by identifying cooperation and duties of main stakeholders;
2. Improve existing or newly-established monitoring and evaluation mechanism with participation from ministries/institutions, communities and developments partners, and improve national and

sub-national technical coordination committee with clear divisions of roles and responsibilities;

3. Capacity building (pre-service and in-service training) for program practitioners, parents, parental power holders and guardians of children on the contents and how to take care of children in line with curriculum and decentralization and deconcentration policy;
4. Develop national and sub-national mechanisms in provision of certificate or recognition letter to program practitioners based on actual care service;
5. Expand services and education on health care and nutrition to all pregnant women;
6. Expand health care and curing services for all infants from birth to three years with regular health checkup, timely and adequate provision of immunization and monitoring on nutrition provision services for children with malnutrition, chronic illnesses, delayed development and disabilities.
7. Extend early childhood care and development services provision, including state, community, private and home based services; especially, early learning for young children.
8. Ensure that all households have access to such information and services as safe water and sanitation, health, nutrition, breast-feeding, food supplementation, immunization, vitamin A, iron and iodized salt, early learning, birth registry, prevention of all types of diseases such as HIV/AIDS, malaria, protection from domestic violence and other forms of vulnerabilities; and
9. Develop communication mechanism on early childhood care and development to attract supports for these services.

## Chapter 3

## POLICY AND IMPLEMENTATION

### I. Policy

The main contents of early childhood care and development Policy are as followings:

1. Ensure the provision of early childhood care and development services from conception to aged under six;
2. Ensure that children have access to holistic early childhood care and development services;

3. Ensure that all concerned ministries, public institutions and civil societies work together for early childhood care and development.

## II. Implementation

Ministry of Education, Youth and Sport plays a crucial role in leading and coordinating with relevant ministries/institutions, development partners and civil societies to cooperatively carry out roles and responsibilities for effective support on early childhood care and development.

1. **Ministry of Education, Youth, and Sport**
    - 1.1 Develop documents and game materials for early childhood care and development;
    - 1.2 Provide preschool techniques and other early childhood development programs to be used as a model for implementation;
    - 1.3 Develop various standards for ECCD (game materials, children park/playground...);
    - 1.4 Ensure quality of ECCD through the quality of training to preschool teachers, facilitators and other relevant workers;
    - 1.5 Communicate on how to use game materials to ensure safety for young children; and
    - 1.6 Coordinate the implementation of ECCD program with involved ministries/institutions.

2. **Ministry of Health**
    - 2.1 Technical coordination with Ministry of Education, Youth and Sport to develop resource materials on health and nutrition, and train facilitators including preschool teachers;
    - 2.2 Educate parents on care for the health of mothers and infants, including importance of breast-feeding and adequate intake of iodine, iron and folic acid, vitamin A and other micronutrients;
    - 2.3 Incorporate ECCD component into the training of nurses and other health workers;
    - 2.4 Ensure vaccination/immunization provision, and other survival and growth rights of all children;
    - 2.5 Ensure health and physical development of children through basic health provision; and
    - 2.6 Provide technical resources and involve in community health education.

3. **Ministry of Interior**
   3.1 Encourage, monitor and support commune/sangkat councils (commune committee for women and children) to implement guideline of the ministry;
   3.2. Cooperate with ministries, institutions, and development partners to update the guideline for commune/sangkat councils to implement ECCD policy;
   3.3. Get involved in evaluation of ECCD services; and
   3.4. Encourage commune/sangkat councils to pay attention on ECCD-related priority needs and include them into commune/sangkat development plan and commune/sangkat investment program.

4. **Ministry of Women's Affairs**
   4.1 Encourage, support, enhance and establish quality ECCD services for general households in need of these services, especially working mothers who need people to take care of their children through networking with various royal government institutions and development partners;
   4.2 Communicate the importance of education of women and girls to ensure gender equality and equity at all levels and the important of ECCD to raise awareness on women's right and child's rights by using all means; and
   4.3 Improve capacity of officials at all levels, commune/sangkat committee for women and children, facilitators, caregivers, volunteers and parents in the communities on primary health care services, life skills and gender mainstreaming.

5. **Ministry of Information**
   5.1 Develop mass media campaigns for dissemination of ECCD-related information.
   5.2 Expand and strengthen the mass media, which plays an important role to raise awareness on child's rights, including ECCD issues, to disseminate information on parent education
   5.3 Develop quality programs for education and entertainment of children.

**6. Ministry of Social Affairs, Veterans and Youth Rehabilitation**

6.1. Support the implementation of alternative care policies and other standards on alternative care for children in the centers and in communities;

6.2. Encourage that orphans, parentless children, disable children, and children with no relatives obtain continual parenting services in the state orphanages or NGO-supported centers where accommodation, health care, vocational training and integration are provided;

6.3. Encourage that child caretakers receive training services on psychology and skill on child care;

6.4. Encourage that all preschool age children living in state orphanages and NGO-supported orphanages or communities are going to preschool to prepare for primary school;

6.5. Integrate ECCD into community-based rehabilitation programs/community-based child protection network and other ministry programs;

6.6. Encourage advocacy on inclusion of children needs into national development plan at all levels.

6.7. Continue to strengthen activities of the Cambodian National Council for Children (CNCC) which is a coordination mechanism among relevant institutions on child protection.

**7. Ministry of Rural Development**

7.1 Encourage provincial/municipal Rural Development Departments to coordinate, monitor and support relevant commune/sangkat councils and commune committee for women and children;

7.2 Collaborate with relevant institutions to strengthen Village Development Committees to enable them to identify means to solve challenges in their communities through access to safe water, hygiene, food security, nutrition, sanitation, and rural credit.

7.3 Promote the construction of rural infrastructure through road construction, access to water supply, sanitation's latrines and hygiene for well-beings of women and children.

**8. The Ministry of Economy and Finance**

The Ministry of Economy and Finance is responsible for ECCD by providing timely funding for ECCD activities.

**9. The Ministry of Planning**

9.1 Facilitate and compile national indicators for setting ECCD targets;

9.2 Facilitate and approve on principles, methodologies and data collection for monitoring and evaluating the implementation of plans and programs which have been identified;

9.3 Facilitate and compile the ECCD plans to be a national plan; and

9.4 Disseminate national figures and indicators resulted from plan implementation and goals for wider and effective ECCD.

**10. Ministry of Agriculture, Forestry, and Fisheries**

10.1 Encourage and improve the agricultural productivity and diversification for parents, parental power holders and guardians through agricultural communication agents at all levels;

10.2 Enhance and strengthen capacity of village agricultural communication agents or domestic animal health care agents and local communities to help parents, parental power holders and guardians to have basis for optimizing their agricultural productivity based on their available resources including vegetable garden development, livestock production and growing varieties of crops in their yard;

10.3 Build capacity of parents of how to maintain and use supplementary elements to increase production of food based on appropriate technology to ensure food security for both users and consumers, especially children; and

10.4 Pay attention on using all means to disseminate agricultural information for the sake of women and children such as promoting awareness on bird flu, safe uses of agricultural chemicals, agricultural fertilizers etc.

**11. Ministry of Environment**

11.1 Parents or guardians shall be the role models in environmental protection so that young children are able to see and understand the importance of the environment;

11.2 Communicate to communities, parents and guardians on the importance of health impacts and how to properly keep poisonous substances used for vegetation to ensure safety for users and environment, especially young children;

11.3 Promote health environment for the sake of citizens', especially women's and children's welfare;

11.4 Prevent and protect all types of environmental pollution, which adversely impact early childhood care and development;
11.5 Communicate and raise awareness among parents, guardians and teachers so that they can educate young children to engage in cleaning environment at home, at school, at public places and on impact on welfare and hazards.

**12. Parents and families**

12.1 Seek necessary knowledge and skills in parenting their children;
12.2 Send children to ECCD programs where available;
12.3 Show their own need to contribute to the establishment of ECCD programs in their village and share their experiences to other households;
12.4 Monitor and evaluate children physical and intellectual development;
12.5 Refrain from committing domestic violence, especially on young children.

**13. Development partners and civil society**

13.1 Support formal and non-formal community-based ECCD services;
13.2 Support new models of ECCD programs by closely cooperating with the Royal Government;
13.3 Support training courses for preschool teachers, ECCD facilitators and parents;
13.4 Build network with other development partners working on ECCD to share information and experiences; and
13.5 Support and provide assistance to ECCD programs targeted at the poor and disadvantaged areas.

# CONCLUSION

Early childhood care and development is the most concerned issue as young children are vulnerable to risks.

The following requirements are needed to realize this policy:

- Mechanism/legal framework to establish a National Committee on ECCD and a Technical Coordination Committee. These documents are included with several necessary requirements such as management structures, roles/responsibilities of the National Committee on ECCD and the Technical Coordination Committee and responsibilities of concerned ministries, institutions, and development partners;
- Prepare national plan to promote ECCD with inclusion of detailed activities and budget; and
- Mobilize supports from all stakeholders.

Concerned ministries, institutions and authorities at all levels shall contribute to highly effective improvement and implementation of national policy on ECCD and shall widely disseminate the contents of the policy to people and development partners with an aim to encourage their involvement in successful implementation of the policy.

# ANNEX

1. **Cambodian National Council for Children**
   A mechanism, which is mandated to consult, coordinate, communicate, prepare reports, monitor and evaluate the implementation of the Convention on the Right of the Child.

2. **National Committee for Early Childhood Care and Development**
   A mechanism responsible for implementing the National Policy on Early Childhood Care and Development to respond to the Law on Education, in line with the Constitution of the Kingdom of Cambodia.

3. **Consultative Committee on Women and Children**
   This committee has the rights and is mandated to give comments and recommendations to councils, board of governors, governors and other committees under the councils in terms of issues related to gender equality, and women and children, which are under the mandate of the councils.